# مقدمة وغلاف المنتقى من موسوعة الأحاديث النبوية

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

សេចក្តីផ្តើម

الحمد لله رب العالمين، وصلى الله وسلم على نبينا محمد، وعلى آله وصحبه أجمعين، ومن تبعهم بإحسان إلى يوم الدين، أما بعد:

ជាការពិតណាស់ អ្វីដែលចាំបាច់លើជនមូស្លីមត្រូវយកចិត្តទុកដាក់(បន្ទាប់គម្ពីររបស់អល់ឡោះ) គឺការអាន ត្រិះរិះពិចារណា សិក្សាស្វែងយល់ និងអនុវត្តតាមស៊ុណ្ណះរ៉សូលុលឡោះ ﷺ ។ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«تركتُ فيكم أيُّها الناس، ما إنِ اعتصمتم به، فلن تضلُّوا أبدًا: كتاب الله، وسُنَّة نبيِّه»

“ឱមនុស្សទាំងឡាយ! យើងបានបន្សល់ទុកឲ្យពួកអ្នកនូវអ្វីដែលប្រសិនបើពួកអ្នកប្រកាន់ខ្ជាប់នឹងវា នោះពួកអ្នកនឹងមិនវង្វេងជាដាច់ខាត គឺគម្ពីររបស់អល់ឡោះ និងស៊ុណ្ណះណាពីរបស់ទ្រង់”។ [រាយការណ៍ដោយ អ៊ីម៉ាំម៉ាលិក]

អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូល៖

{وَمَا آتَاكُمُ الرَّسُولُ فَخُذُوهُ وَمَا نَهَاكُمْ عَنْهُ فَانْتَهُوا}

“ហើយអ្វីដែលអ្នកនាំសារបានផ្តល់ឱ្យពួកអ្នក ចូរពួកអ្នកទទួលយកវាចុះ ហើយអ្វីដែលគាត់បានហាមឃាត់ពួកអ្នកអំពីវា ចូរពួកអ្នកបោះបង់ចោល”។ [អាល់ហាស្ហ៍រ៖៧]

អាស្រ័យហេតុនេះហើយទើបសមាគមបម្រើមាតិកាឥស្លាមពហុភាសា និង

សមាគមផ្សព្វផ្សាយនិងអប់រំសហគមន៍នៃតំបន់រ៉ប់វ៉ះ បានយកចិត្តទុកដាក់រៀបចំនូវសព្វវចនាធិប្បាយហាទីស្ហណាពី ﷺ និងធ្វើការប្រែសម្រួលទៅជាភាសាជាច្រើន។

ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានសម្រួលនៅក្នុងការដកស្រង់នូវហាទីស្ហសំខាន់ៗជាច្រើនចេញពីសព្វវចនាធិប្បាយនេះដែលជនមូស្លីមត្រូវការចំពោះវាទាំងផ្នែកសាសនាចក្រនិងអាណាចក្រ និងធ្វើការពន្យល់ដោយសង្ខេប រួមជាមួយនឹងមេរៀនដែលដកស្រង់ចេញពីហាទីស្ហទាំងនោះ ហើយបានរៀបចំវាជាសៀវភៅនេះដែលយើងឲ្យឈ្មោះថា៖ “សម្រង់ហាទីស្ហណាពី ﷺ ពីសព្វវចនាធិប្បាយហាទីស្ហណាពី” យើងបានប្រែសម្រួលហាទីស្ហទាំងនោះទៅជាភាសាជាច្រើនដែលត្រូវបាននិងកំពុងប្រើប្រាស់នៅលើពិភពលោកដើម្បីឲ្យមនុស្សទាំងឡាយអាចទាញយកប្រយោជន៍ពីវា ក៏ដូចជាធ្វើការផ្សព្វផ្សាយស៊ុណ្ណះរ៉សូលុលឡោះ ﷺ ទៅកាន់មនុស្សជាតិទៅតាមភាសារបស់ពួកគេ។

សូមអល់ឡោះជាម្ចាស់មេត្តាទទួលយកកិច្ចការនេះ និងសូមឲ្យវាក្លាយជាការងារមួយដែលមានពរជ័យប្រកបដោយភាពជ្រះថ្លាចំពោះទ្រង់ ហើយសូមទ្រង់មេត្តាប្រទានផលបុណ្យដល់អ្នកទាំងឡាយដែលបានជួយលើការរៀបចំការងារនេះ

ការប្រែសម្រួលហាទីស្ហ
ក៏ដូចជាផ្សព្វផ្សាយវាទៅកាន់មនុស្សទាំងឡាយ។

وصلى الله وسلم على نبينا محمد

សង្ខេប

ហាទីស្ហណាពី ﷺ
គឺជាប្រភពទីពីរនៅក្នុងការបញ្ញត្តិច្បាប់ផ្សេងៗនៅក្នុងសាសនាឥស្លាម។
អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

{وَمَا يَنْطِقُ عَنِ الْهَوَى (٣) إِنْ هُوَ إِلَّا وَحْيٌ يُوحَى}

“ហើយគាត់(មូហាំម៉ាត់)ក៏មិននិយាយតាមទំនើងចិត្តដែរ។

អ្វីដែលគាត់និយាយគ្មានអ្វីក្រៅពីវ៉ាហ៊ីដែលត្រូវគេវ៉ាហ៊ីមកនោះឡើយ”។ [អាន់ណាចម៍៖៣-៤]

នេះជាសម្រង់ហាទីស្ហណាពី ﷺ
ដែលយើងបានធ្វើការដកស្រង់ចេញពីសព្វវចនាធិប្បាយហាទីស្ហណាពី ﷺ
ដែលផ្ទុកទៅដោយហាទីស្ហសំខាន់ៗជាច្រើនដែលជនមូស្លីមត្រូវការចំពោះវាទាំងផ្នែកសាសនាចក្រនិងអាណាចក្រ ហើយបានធ្វើការពន្យល់ដោយសង្ខេបរួមជាមួយនឹងមេរៀនដែលដកស្រង់ចេញពីហាទីស្ហទាំងនោះដោយបានធ្វើការប្រែសម្រួលទៅជាភាសាជាច្រើនដែលគេកំពុងប្រើប្រាស់នៅលើពិភពលោកដើម្បីឲ្យមនុស្សទាំងឡាយអាចទាញយកប្រយោជន៍ពីវា

ព្រមទាំងធ្វើការផ្សព្វផ្សាយស៊ុណ្ណះរ៉ស៊ូលុលឡោះ ﷺ ទៅកាន់មនុស្សជាតិទៅតាមភាសារបស់ពួកគេ។

# Index

No table of contents entries found

km375v1.0 - 04/09/2026